**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Apr-2017, 15:28
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

# សំណើរបស់សហព្រះរាជអាជ្ញា សុំកែសម្រួលកាលវិភាគសម្រាប់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០២

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្ដារ

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**
លោកស្រី ទូច វណ្ណ័ក្ស
លោក Calvin SAUNDERS

## ប្រវត្តិ និង សំណើ

1. សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០២ បច្ចុប្បន្នត្រូវបានកំណត់ពេលដាក់ត្រឹមថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ ចំណែកសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ត្រូវបានកំណត់កាលបរិច្ឆេទដាក់ក្នុងរយៈពេល១០ថ្ងៃ ក្នុងដំណើរការសវនាការ ចាប់ពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៧ ប្រហែលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧[1]។ ក្នុងពេលជាមួយគ្នានេះ ប្រតិចារឹកមួយចំនួនត្រូវបានកំណត់អត្តសញ្ញាណសម្រាប់អាទិភាពកែតម្រូវដោយអង្គជំនុំជម្រះ ហើយ ខៀវ សំផន នៅមិនទាន់បានពិនិត្យ និងកែសម្រួលនៅឡើយ ហើយដំណើរការនោះមិនរំពឹងថា នឹងអាចបញ្ចប់បានទេរហូតដល់ពីរបីថ្ងៃមុន (ចំពោះភាសាអង់គ្លេស និងបារាំង) ឬពីរបីថ្ងៃក្រោយ (ចំពោះភាសាខ្មែរ) កាលបរិច្ឆេទកំណត់បច្ចុប្បន្នសម្រាប់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល[2]។ ជាការបន្ថែមចំនួនប្រតិចារឹកសវនាការមួយចំនួនធំជាងនេះ នៅមិនទាន់បានឆ្លងកាត់ដំណើរការរបស់អង្គភាពបកប្រែដើម្បីត្រួតពិនិត្យពីគុណភាព និងកែតម្រូវលើកំហុសឆ្គងក្នុងការបកប្រែផ្ទាល់មាត់នៅឡើយ[3] ដែលអង្គជំនុំជម្រះបានសម្រេចថា "ចាំបាច់ដើម្បីធានាកំណត់ហេតុសវនាការគួរឱ្យទុកចិត្តបាន"[4]។

2. នួន ជា ធ្លាប់បានដាក់ពីមុននូវសំណើមួយដោយមានការគូសបញ្ជាក់ពីការលំបាកនានានៃដំណើរការពិនិត្យមានចំពោះមេធាវីការពារក្តី នៅចំពេលដែលខ្លួនកំពុងធ្វើសេចក្តីព្រាងសារណាបញ្ចប់កិច្ច

---

[1] **E449/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី: "សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និង សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០២", ១៦ ធ្នូ ២០១៦, កថាខណ្ឌ១០-១១។ ថ្ងៃបញ្ចប់ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ នេះ គឺត្រូវបានគណនាដោយផ្អែកលើការសន្មត់ ថ្ងៃសវនាការមានចំនួនបួនថ្ងៃក្នុងមួយសប្តាហ៍។

[2] **E449/3/3** អនុស្សរណៈអន្តរការិយាល័យពីប្រធានរដ្ឋបាលស្តីទី និងអនុប្រធានរដ្ឋបាល ស្តីពី: "ចម្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧", ២៧ មីនា ២០១៧, កថាខណ្ឌ២៩។ ប្រតិចារឹកដែលបានកែតម្រូវ ត្រូវបានគេរំពឹងថា នឹងអាចរកបានជាភាសាអង់គ្លេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៧, ជាភាសាបារាំង ថ្ងៃទី២១ មេសា ២០១៧ និងជាភាសាខ្មែរ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧។

[3] **E449/3/3** អនុស្សរណៈអន្តរការិយាល័យពីប្រធានរដ្ឋបាលស្តីទី និងអនុប្រធានរដ្ឋបាល ស្តីពី: "ចម្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧", ២២ មីនា ២០១៧, កថាខណ្ឌ២។

[4] **E449/3/6** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងកាលបរិច្ឆេទកំណត់សម្រាប់ការពិនិត្យមើលប្រតិចារឹកឡើងវិញជាចុងក្រោយ", ៣ មេសា ២០១៧ ("អនុស្សរណៈ ចុះថ្ងៃទី៣ មេសា ២០១៧"), កថាខណ្ឌ៥។

ពិភាក្សាដេញដោល[5] ហើយអង្គជំនុំជម្រះបានទទួលស្គាល់ពីសារសំខាន់នៃបន្ទុកនេះ[6]។ សហព្រះរាជអាជ្ញាក៏ជួបការលំបាកដូច្នេះដែរ។

3. សហព្រះរាជអាជ្ញាយល់ឃើញយ៉ាងមុតមាំថា ពេលបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ មិនគួរពន្យារពេលច្រើននោះទេ ប្រសិនបើការពន្យារពេលអាចជៀសវាងបាន។ ក្នុងពេលជាមួយគ្នានេះដែរ សហព្រះរាជអាជ្ញាយល់ឃើញថា ការលំបាកនានាដែលបណ្ដាលមកពីដំណើរការពិនិត្យផ្ទៀងផ្ទាត់ប្រតិចារឹកអាចសម្រួលបានយ៉ាងច្រើន តាមរយៈការកែសម្រួលកាលវិភាគដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល តាមវិធីមួយដែលមិនធ្វើឱ្យមានការពន្យាពេលកិច្ចដំណើរការនីតិវិធីច្រើនហួស។ យ៉ាងជាក់លាក់នោះ សហព្រះរាជអាជ្ញាយល់ឃើញថា កាលបរិច្ឆេទកំណត់សម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលគួរត្រូវបានបន្ថយពេល ១៥ថ្ងៃ មកត្រឹមថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧។ សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលគួរចាប់ផ្ដើមនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៧ ជាជាងថ្ងៃទី៥ ខែមិថុនា ប៉ុន្តែពេលវេលាដែលមានសម្រាប់ភាគីទាំងអស់គួរកាត់បន្ថយយ៉ាងសមមាត្រគ្នា ដើម្បីអនុញ្ញាតឱ្យកិច្ចដំណើរការនីតិវិធីបញ្ចប់នៅពេលដូចដែលបានគ្រោងទុកបច្ចុប្បន្ន ឬ យ៉ាងហោចណាស់មិនហួសពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧។

4. អង្គជំនុំជម្រះសាលាដំបូងបានបែងចែកចំនួនទំព័រកំណត់យ៉ាងច្រើន ដើម្បីអនុញ្ញាតឱ្យភាគីនានាដាក់ករណីរបស់ខ្លួនឱ្យបានពេញលេញមកកាន់អង្គជំនុំជម្រះ។ ដូចដែលបានគ្រោងទុកអំណះអំណាងផ្ទាល់មាត់ មិនមែនជាឱកាសសម្រាប់ភាគីនានាថាឡើងវិញនូវសេចក្ដីសន្និដ្ឋានដ៏វែងអន្លាយនៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួននោះទេ ប៉ុន្តែផ្ទុយទៅវិញ គឺត្រូវឆ្លើយតបទៅនឹងសារណានានាដែលបានដាក់ដោយភាគីផ្សេងៗទៀត។ ប្រសិនបើភាគីប្រើពេលវេលាដែលបានបែងចែកឱ្យភាគីនីមួយៗបច្ចុប្បន្ននេះ អំណះអំណាងបិទកិច្ចពិភាក្សាដេញដោលនឹងចំណាយពេលតុលាការចំនួនដប់ថ្ងៃ។ បើសិនជាអង្គជំនុំជម្រះមានបំណងរក្សាទុកកាលវិភាគសវនាការបួនថ្ងៃក្នុងមួយសប្ដាហ៍ ដែលត្រូវបានប្រើក្នុងពេលជំនុំជម្រះនោះ អំណះអំណាងផ្ទាល់មាត់នឹងបញ្ចប់ក្នុងរយៈពេលពីរសប្ដាហ៍កន្លះ។ ការនេះនឹងមានរយៈពេលយូរជាងពេលវេលា ដែលជាធម្មតាត្រូវបាន

[5] **E449/3** សំណើបន្ទាន់តាមវិធាន ៩២ របស់ នួន ជា ទាក់ទងនឹងកាលកំណត់នៃប្រតិចារិកដែលកែតម្រូវជាស្ថាពរ, ១៥ មីនា ២០១៧, កថាខណ្ឌ១៤-១៨។

[6] **E449/3/6** 3 អនុស្សរណៈ ចុះថ្ងៃទី៣ មេសា ២០១៧, កថាខណ្ឌ៥។

បែងចែកក្នុងការជំនុំជម្រះដ៏ស្មុកស្មាញនានា នៅតាមតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត។ សហព្រះរាជអាជ្ញាយល់ឃើញថា ទោះបីជាកាត់បន្ថយពេលដែលបែងចែកឱ្យភាគនានាចំនួន ៥០% ក៏នៅមានពេលគ្រប់គ្រាន់ (ប្រាំថ្ងៃសវនាការ) សម្រាប់ភាគីនីមួយៗដើម្បីពន្យល់ឱ្យបានពេញលេញ អំពីអំណះអំណាងសំខាន់ៗរបស់ខ្លួន ក្នុងការជំទាស់ទៅនឹងសារណារបស់ភាគីផ្សេងទៀតបានដែរ ខណៈដែលអនុញ្ញាតឱ្យអំណះអំណាងទាំងនោះបញ្ចប់ត្រឹមថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧។ សូម្បីតែការបែងចែកពេលវេលាត្រូវបានកាត់បន្ថយត្រឹមតែ ២០% ក៏ដោយ ក៏អំណះអំណាងទាំងនោះគួរអាចត្រូវបានបញ្ចប់ក្នុងរយៈពេលពីរសប្តាហ៍ គឺត្រឹមថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧។

5. វិធីសាស្ត្រនេះនឹងផ្តល់ដល់ភាគីនានានូវឱកាសដែលមានអត្ថន័យ ដើម្បីពិនិត្យមើលជាចុងក្រោយ ពិនិត្យមើលឡើងវិញ កែតម្រូវ នូវសំណៅប្រតិចារឹកដែលអង្គជំនុំជម្រះ និង ខៀវ សំផន បានកំណត់អត្តសញ្ញាណជាអាទិភាព ដែលអាចត្រូវបានសន្មតថាមានទាក់ទងយ៉ាងសំខាន់ជាសក្តានុពល ទៅនឹងបញ្ហានានាដែលមានវិវាទ។ វានឹងអនុញ្ញាតផងដែរដល់អង្គភាពបកប្រែភាសាបានបំពេញនូវការត្រួតពិនិត្យគុណភាពរបស់ខ្លួន និងនីតិវិធីកែតម្រូវសម្រាប់ប្រតិចារឹកមួយចំនួនធំ នៅមុនការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងអនុញ្ញាតឱ្យភាគីនានាយកធ្វើជាមូលដ្ឋានរបស់ពួកគេសម្រាប់សារណា នៅលើផ្នែកសំខាន់ដ៏ធំនៃប្រតិចារឹកចុងក្រោយ ដែលបានពិនិត្យមើលសារឡើងវិញ និង ដែលបានកែតម្រូវ។ នៅពេលជាមួយគ្នានោះ វានឹងរក្សាសបាននូវឱកាសភាគច្រើនរវាងការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងការចេញនូវសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលដែលភាគីនានានឹងត្រូវការជាចាំបាច់ ដើម្បីរៀបចំរូបមន្តឆ្លើយតបទៅនឹងអំណះអំណាងដែលបានធ្វើឡើងដោយភាគីផ្សេងៗទៀត។ ខណៈដែលវានឹងកាត់បន្ថយបន្តិចបន្តួចនូវចំនួនពេលវេលាដែលអាចមានបាន សម្រាប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល នោះថ្ងៃសវនាការដែលមានរយៈពេលពីប្រាំ ទៅប្រាំបីថ្ងៃ ដែលអាចមានបានសម្រាប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល នឹងនៅតែលើសនៅឡើយលើចំនួនពេលវេលាដែលអាចមានបានសម្រាប់អំណះអំណាងផ្ទាល់មាត់នៅក្នុងករណីស្រដៀងគ្នា នៅឯតុលាការអន្តរជាតិផ្សេងៗទៀត ហើយដូច្នេះ ទំនងជាមិនបណ្តាលឱ្យមានការខូចខាតប្រយោជន៍ដល់ភាគីណាមួយឡើយ។

6. អនុលោមតាមមាត្រា៧.២ នៃសេចក្តីណែនាំអនុវត្តដែលពាក់ព័ន្ធ[7] សហព្រះរាជអាជ្ញាក៏បានស្វែងរកស្នើសុំការអនុញ្ញាតផងដែរ ដើម្បីឱ្យបានដាក់សំណើនេះជាភាសាអង់គ្លេសមួយតែប៉ុណ្ណោះ ដោយ

[7] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក, អវតក/០១/២០០៧/ វិ.លើកទី៨, ៧ មីនា ២០១២,មាត្រា៧.២។

មានការបកប្រែជាភាសាខ្មែរតាមក្រោយ យ៉ាងឆាប់បំផុត។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ភាពប្រញាប់នៃការបរិច្ឆេទកំណត់ដាក់ដែលបានពន្យារ និងការចាំបាច់របស់អង្គជំនុំជម្រះក្នុងការស្តាប់ភាគីផ្សេងៗទៀតលើបញ្ហានេះ បង្កើតបានជាកាលៈទេសៈពិសេសមួយ ដែលបានតម្រូវដោយមាត្រានោះ។

7. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះ ៖

ក- ផ្តល់ការអនុញ្ញាតដាក់សំណើសុំនេះជាភាសាអង់គ្លេសតែមួយសិន ចំណែកច្បាប់បកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

ខ- កំណត់កាលបរិច្ឆេទសម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧។

គ- កំណត់កាលវិភាគសម្រាប់ការផ្តល់ជូនសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល គិតចាប់ផ្តើមពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ ហើយនឹង

ឃ- កាត់បន្ថយពេលវេលាឲ្យសមាមាត្រទៅនឹងពេលវេលាដែលភាគីនិមួយៗមាន ឲ្យបាន ៥0% ឬតិចជាងនេះ សម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដើម្បីអាចឲ្យកិច្ចដំណើរការនីតិវិធីបញ្ចប់មិនឲ្យលើសពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |